Disability Rights California

*California's protection & advocacy system*
*Toll-Free (800) 776-5746*

# ការទទួលបានការគាំទ្រផ្នែកទំនាក់ទំនងតាមរយៈ California Department of Rehabilitation (DOR) (នាយកដ្ឋានស្តារនីតិសម្បទារដ្ឋកាលីហ្វ័រញ៉ា)

*តុលា 2019 ឯកសារបោះពុម្ពផ្សាយ #7149.06 - Cambodian*

## 1. ឧទាហរណ៍អំពីការគាំទ្រផ្នែកទំនាក់ទំនង

"ការគាំទ្រផ្នែកទំនាក់ទំនង" គឺជាឧបករណ៍អេឡិចត្រូនិក ឬសេវាកម្មដែលអាចជួយដល់បុគ្គលដែលមានពិការភាពក្នុងការប្រាស្រ័យទាក់ទង។ ឧទាហរណ៍ Augmentative and Alternative Communication (AAC) (វិធីសាស្ត្រទំនាក់ទំនងបន្ថែម និងជំនួស), Assistive Technology (AT) (បច្ចេកវិទ្យាជំនួយ) ឬ "Special Adaptive Equipment," (ឧបករណ៍សម្របសម្រួលពិសេស) គឺជាឧបករណ៍អេឡិចត្រូនិក ដែលអាចជួយឲ្យបុគ្គលម្នាក់ប្រាស្រ័យទាក់ទងគ្នាបាន។ នៅក្នុងប្រព័ន្ធរបស់ Department of Rehabilitation (DOR) (នាយកដ្ឋានស្តារនីតិសម្បទា) ឧបករណ៍អេឡិចត្រូនិកទាំងនេះ ត្រូវបានគេហៅថា "rehabilitation technology" (បច្ចេកវិទ្យាស្តារនីតិសម្បទា) និងរួមបញ្ចូលនូវ "assistive technology devices" (ឧបករណ៍អេឡិចត្រូនិកបច្ចេកវិទ្យាជំនួយផងដែរ)។

ខាងក្រោមនេះ គឺជាឧទាហរណ៍មួយចំនួនអំពីការគាំទ្រផ្នែកទំនាក់ទំនង៖

- JAWs (Job Access with Speech) (ការងារទទួលបានតាមសម្តី) និងប្រភេទផ្សេងទៀតនៃបច្ចេកវិទ្យាអានអក្សរលើអេក្រង់ឧបករណ៍អេឡិចត្រូនិក។
- ឧបករណ៍ Dynavox (ឌីណាវ៉ុក) និង Speech Generating Devices (SGDs) (ឧបករណ៍បង្កើតសម្តី) ដទៃផ្សេងទៀត។
- PECs (Picture Exchange Communication System)

(ប្រព័ន្ធទំនាក់ទំនងទៅវិញទៅមកដោយប្រើរូបភាព) និងទម្រង់ផ្សេងទៀតនៃប្រព័ន្ធទំនាក់ទំនងផ្អែកតាមរូបភាព។

- ផ្ទាំងតួអក្សរ ឬផ្ទាំងអក្ខរក្រម។
- ឯកសារជាអក្សរស្ទាប ឬអក្សរពុម្ពធំ។
- សេវាកម្មនានាដូចជា អ្នកបកប្រែភាសាសញ្ញា ឬដៃគូប្រាស្រ័យទាក់ទង។
- ការអានឯកសារឲ្យឮៗ។
- ឯកសារដែលបានផ្តល់ជូនជាមុន/ផ្តល់ពេលបន្ថែមដើម្បីត្រួតពិនិត្យ៖
- ឯកសារសរសេរជាភាសាដែលងាយស្រួលយល់។
- ការប្រើប្រាស់អ្នកបកប្រែ ឬឧបករណ៍អេឡិចត្រូនិកជំនួយផ្សេងទៀត។

## 2. ការទទួលបានការគាំទ្រផ្នែកទំនាក់ទំនងពី DOR

DOR អាចបង់ប្រាក់សម្រាប់ថ្លៃ “rehabilitation technology” (បច្ចេកវិទ្យាស្តារនីតិសម្បទា) ដែលមានភាពចាំបាច់សម្រាប់អ្នកដើម្បីទទួលបានសេវាកម្មរបស់ DOR និងដើម្បីសម្រេចបាននូវគោលដៅការងាររបស់អ្នក។ DOR អាចផ្តល់ជូនដល់អ្នកនូវការវាយតម្លៃណាមួយ ដើម្បីពិនិត្យមើលថាតើឧបករណ៍បច្ចេកវិទ្យាជំនួយ នឹងអនុញ្ញាតឲ្យអ្នកធ្វើកិច្ចការណាមួយ ឬដើម្បីជួយឲ្យមានភាពងាយស្រួលជាងមុន ឬមានសុវត្ថិភាពជាងមុនសម្រាប់អ្នកក្នុងការបំពេញកិច្ចការជាក់លាក់ណាមួយ។ សេវាកម្មបច្ចេកវិទ្យាជំនួយដែល DOR អាចផ្តល់ជូនបាន អាចរួមបញ្ចូលនូវការទិញ ការជ្រើសរើស ការកែតម្រូវ និងការបណ្តុះបណ្តាលអ្នក (និងមនុស្សដទៃទៀតតាមសមស្រប) ស្តីពីរបៀបប្រើប្រាស់ឧបករណ៍ អេឡិចត្រូនិកនេះ។ ប្រសិនបើអ្នកជាអតិថិជនរបស់ DOR និងមានពិការភាពដែលតម្រូវឲ្យមានការគាំទ្រផ្នែកទំនាក់ទំនងដើម្បីសម្រេចបាននូវគោលដៅការងាររបស់អ្នក ការគាំទ្រនិងសេវាកម្មទាំងនោះ គប្បីត្រូវរួមបញ្ចូលនៅក្នុង Individualized Plan for Employment (IPE) (ផែនការការងារសម្រាប់បុគ្គល) ក្នុងនាមជាបច្ចេកវិទ្យាស្តារនីតិសម្បទា។

សម្រាប់ព័ត៌មានបន្ថែមស្តីពីសិទ្ធិក្នុងការទទួលបានការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពពីកម្មវិធីរបស់រដ្ឋាភិបាលដូចជា DOR ជាដើម សូមមើល U.S. Department of Justice (ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក) *លក្ខខណ្ឌតម្រូវរបស់ ADA៖ ការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព* https://www.ada.gov/effective-comm.htm។

## 3. តើត្រូវដាក់បណ្តឹងឧទ្ធរណ៍ដើម្បីបដិសេធការគាំទ្រផ្នែកទំនាក់ទំនងដោយរបៀបណា?

អ្នកអាចស្នើសុំការត្រួតពិនិត្យផ្នែករដ្ឋបាល ឬការស្រុះស្រួល និង/ឬសវនាការដោយយុត្តិធម៌។ សម្រាប់ព័ត៌មានបន្ថែមអំពីបណ្តឹងឧទ្ធរណ៍របស់ DOR សូមមើល *សន្លឹកខិត្តប័ណ្ណព័ត៌មានអំពីដំណើរការនិងជម្រើសក្នុងការប្តឹងឧទ្ធរណ៍របស់ California Department of Rehabilitation (នាយកដ្ឋានស្តារនីតិសម្បទារដ្ឋកាលីហ្វ័រញ៉ា),ឯកសារបោះពុម្ពផ្សាយ #5530.01* នៅ

[https://www.disabilityrightsca.org/publications/california-department-of-rehabilitation-appeals-options-process-fact-sheet](https://www.disabilityrightsca.org/publications/california-department-of-rehabilitation-appeals-options-process-fact-sheet)

*Disability Rights California (អង្គការសិទ្ធិជនពិការរដ្ឋកាលីហ្វ័រញ៉ា) បានរៀបចំខិត្តប័ណ្ណព័ត៌មាននេះសម្រាប់ជាផ្នែកមួយនៃគម្រោង* Communication *Disabilities Access Network (បណ្តាញដើម្បីទទួលបានការប្រាស្រ័យទាក់ទងសម្រាប់ជនពិការ )។ គម្រោងនេះ គឺដើម្បីផ្តើត បណ្តុះបណ្តាល និងដំណើរការបណ្តាញថ្នាក់ដឹកនាំមួយដើម្បីធ្វើការផ្សព្វផ្សាយគាំពារដល់ការគាំទ្រផ្នែកទំនាក់ទំនង។ គម្រោងនេះ ទទួលបានមូលនិធិពី* Ability Central *(អង្គការលើកកម្ពស់សមត្ថភាព) ដែលពីមុនមកហៅថា* Disability Communications Fund *(មូលនិធិទំនាក់ទំនងសម្រាប់ជនពិការ)។* Ability Central *(អង្គការលើកកម្ពស់សមត្ថភាព) គាំទ្រកម្មវិធីនិងបច្ចេកវិទ្យាដែលផ្តល់ប្រយោជន៍ដល់ការទំនាក់ទំនងនិងទទួលបានព័ត៌មានអំពីតម្រូវការនៃពលរដ្ឋ* California *ដែលមានពិការភាព។ សម្រាប់ព័ត៌មានបន្ថែម សូមមើល* http://dcfund.us/